# សន្លឹកក្រដាសការណ៍ពិត លេខកូដម្ហូប #33

*អ្នកគួរតែដឹងអ្វីខ្លះ អំពីលេខកូដ*

WWW.HEALTHOREGON.ORG/FOODSAFETY

## ការសំអាតធុងទឹក រថលក់ម្ហូបចល័ត

**OAR 333-150-0000, ជំពូក 5-304.15**

**5-304.15 ការសំអាត ធុងទឹក។**
(A) ធុងទឹកចល័ត នៃរថលក់ម្ហូបចល័ត គួរតែបានរៀបចំឡើង អាចលូកបាន និងភ្លឺព្រិលៗ ប្រយោជន៍ឲ្យអាចសំរេចភាពស្អាតស្អំបាន តាមរយៈការត្រួតពិនិត្យមើលដោយភ្នែក។ រថលក់ម្ហូបចល័ត ដែលបានចេញអាជ្ញា ប័ណ្ណមុនថ្ងៃទី 1 ខែកុម្ភៈ 2020 មិនចាំបាច់ជួបការតម្រូវនេះទេ។
(B) ធុងទឹកចល័ត និងទឹកសំណល់ ត្រូវតែបានសំអាត យ៉ាងហោចរៀងរាល់ប្រាំមួយ ខែ ឬដូចបានឲ្យអនុសាសន៍ដោយរោងចក្រ។

**មូលហេតុសុខភាព សាធារណៈ៖**

រថលក់ម្ហូបចល័ត និងទឹកសំណល់ ត្រូវតែបានសំអាតតាមពេលវេលាទៀងទាត់ ដើម្បីជៀសវាងការផ្ដុំឡើងនូវសរីរៈមានជីវិត ឬអាចមានប្រឡាក់អ្វីមួយ។

វាគឺជាសារៈសំខាន់ ដើម្បីសំអាតធុងទឹកសាប នៃរថលក់ម្ហូបចល័តរបស់អ្នក ឲ្យបានញឹកញាប់ ប្រយោជន៍ឲ្យអ្នកដឹងថាទឹកដែលអ្នកកំពុងប្រើ គឺសុខដុម។ យូរៗទៅ ធុងទឹកអាចធ្វើឲ្យមេរោគបាក់តេរីធំធាត់ ដែលអាចធ្វើឲ្យអតិថិជនឈឺថ្កាត់។

**ធុងទឹកសាប និងទឹកសំណល់ ត្រូវតែបានសំអាត យ៉ាងហោចរៀងរាល់ប្រាំមួយ (6) ខែ ឬញឹក ញាប់ជាង បើសិនរោងចក្រផលិតធុងទឹក ឲ្យអនុសាសន៍។**

ការមួយចំនួនដើម្បីគិតគូរ មុននឹងចាប់ផ្ដើម ដំណើរការសំអាត៖

- អ្នកនឹងបំពេញទឹកសាបឲ្យពេញធុងទឹក និងចាក់វាចោលពីរដង (ម្ដងដោយមានទឹកក្លរីន និងម្ដងទៀតដោយមានទឹកថ្លា ដើម្បីលាងជំរះវា)។
- អ្នកនឹងត្រូវនៅក្បែរ ទីតាំងចោលទឹកសំណល់បានយល់ព្រម ឬមានប្រដាប់បូមមានអាជ្ញាប័ណ្ណ ដើម្បីចាក់ទឹកសំណល់របស់អ្នកចេញពីធុងទឹក នៅអំឡុងពេលសំអាត។
- សំរាប់ទឹកមានក្លរីន អ្នកនឹងប្រើល្បាយវារ ម៉្យាងហៅថា សូឌីយ៉ូម ហៃផូក្លរិត (sodium hypochlorite) ដែលមានជាតិក្លរីន 5-8% (ឬទឹក ធ្វើឲ្យស)។ អ្នកត្រូវតែប្រើទឹកធ្វើឲ្យសគ្មានក្លិន ឬគ្មានគ្រឿងថែម។ ទឹកមានក្លរីន នឹងត្រូវទុកឲ្យនៅក្នុងធុងទឹករបស់អ្នក ជាច្រើនម៉ោង ដូច្នេះហើយអ្នក នឹងត្រូវ ធ្វើការនេះ នៅពេលអ្នកបានបិទទ្វារ សំរាប់ជំនួញ។
- ចតរថរបស់អ្នកនៅលើផ្ទៃរាបប្រយោជន៍ឲ្យផ្នែកទាំងអស់នៃធុងទឹក របស់អ្នកនឹងបានសំអាតសព្វទាំងអស់។

ដើម្បីសំអាតធុងទឹក អ្នកនឹងត្រូវបំពេញធុងទឹក សាបរបស់អ្នក ឲ្យពេញទាំងអស់ និងចាក់វាចោល ពីរដង៖ ម្ដងដោយមានទឹកក្លរីន និងម្ដងទៀត ដោយមានទឹកថ្លា សំរាប់ការលាងជំរះ។ មើលទំព័រ 2 សំរាប់ សេចក្ដីណែនាំ។



*ធុងទឹកសាប ត្រូវតែអាចមើលឃើញផ្ទះ និងងាយលូកបាន។ ធុងទឹកនឹង ប្រហែលមិនអាចយកចេញពីរថបានទេ។*

ធ្វើតាមការណែនាំរបស់រោងចក្រ និងបញ្ញត្តិក្នុង តំបន់ នៅពេលលាងសំអាតធុងទឹក នៃរថចល័តរបស់អ្នក។ ហៅអ្នកត្រួតពិនិត្យរបស់អ្នក បើសិន មានសំណួរអ្វីមួយ។ ការថែរក្សាទៀងទាត់ និងការ សំអាតត្រឹមត្រូវ នឹងធ្វើឲ្យប្រាកដថាអ្នកតែងតែ ផ្ដល់ទឹកទៅឲ្យអតិថិជនរបស់អ្នក ប្រកបដោយ សុខដុម។



Oregon Health Authority

## សមាគមកិច្ចការទឹកអាមេរិកាំង ឲ្យអនុសាសន៍ធ្វើតាមជំហានទាំងនេះ ដើម្បីសំអាតធុងទឹកសាបរបស់អ្នក៖

1. គិតលេខចំណុះនៃធុងទឹករបស់អ្នក និងទឹកធ្វើឲ្យសចំនួនប៉ុន្មាន ដែលអ្នកនឹងត្រូវការ សំរាប់ល្បាយរាវទឹកក្លរីន 50ppm។ ប្រដាប់គិតលេខទឹកក្លរីនខាប់ អាចរកឃើញនៅ៖ www.omnicalculator.com/chemistry/bleach-dilution
2. ចាក់ចំនួនត្រឹមត្រូវ នៃទឹកធ្វើឲ្យស ដោយប្រយ័ត្នប្រយែង ចូលទៅក្នុងរន្ធធុងទឹកសាបរបស់អ្នក។ បន្ទាប់មក ថែមទឹក ដើម្បីបំពេញធុងទឹក និងប្រើបន្ទះពិសោធន៍របស់អ្នក ដើម្បីធ្វើឲ្យប្រាកដ ថាអ្នកមានល្បាយរាវទឹកក្លរីន (ទឹកធ្វើឲ្យស) 50 ppm។
3. មួលដៃមួលទាំងអស់ (ក្តៅ និងត្រជាក់) រហូតទាល់តែអ្នកធុំក្លិនទឹកធ្វើឲ្យស និងអាចមើលឃើញទឹកមានក្លរីន 50 ppm ចេញពីក្បាលទឹក នៅពេលប្រើបន្ទះពិសោធន៍របស់អ្នក។ 50 ppm គឺមានពណ៌ខៀវស្រាល/ស្វាយ នៅលើបន្ទះពិសោធន៍ពណ៌ស។
4. បិទដៃមួល និងបណ្តោយឲ្យទឹកនៅស្ងៀម ក្នុងធុងទឹកចំនួនប្រាំមួយ (6) ម៉ោង។
5. ចូរកុំផឹកទឹកនេះ ឬប្រើវាសំរាប់អ្វីៗ នៅក្នុងរថលក់ម្ហូបចល័តរបស់អ្នក សោះឡើយ!
6. បន្ទាប់ពីប្រាំមួយ (6) ម៉ោងមក បង្ហូរធុងទឹកសាប ចូលទៅក្នុងធុងទឹកសំណល់ និងរង់ចាំចំនួន 30 នាទី។
7. ខណៈអ្នកកំពុងរង់ចាំ បំពេញធុងទឹកសាបសាថ្មី ដោយប្រើបំពង់ទឹកថ្នាក់ម្ហូប។ បន្ទាប់មក ក៏ឲ្យទឹកហូរតាមរយៈធុងទឹកសាបរបស់អ្នក មួយដងទៀត បូរហូតទាល់តែក្លិនទឹកធ្វើឲ្យស បានចុះថយ ហើយអ្នកលែងឃើញពណ៌ខៀវ នៅលើបន្ទះពិសោធន៍របស់អ្នកទៀត។
8. វាមិនគ្រោះថ្នាក់ទេ បើសិនអ្នកនៅតែមានក្លិនទឹកធ្វើឲ្យសតិចៗ និងមានរសជាតិ ដរាបណាអ្នកបានប្រើល្បាយរាវទឹកក្លរីនត្រឹមត្រូវតាមចំនួន។

## គំរូនៃបញ្ជីការសំអាត៖

| | |
|---|---|
| ឈ្មោះនិយោជិត៖ | ទំហំធុងទឹកសាប (ហ្គាឡុង)៖ |
| កាលបរិច្ឆេទ៖ | ចំនួននៃទឹកក្លរីនធ្វើឲ្យស ដើម្បីប្រើ៖ |

| កាលបរិច្ឆេទ៖ | ទឹកក្លរីនខាប់ (ppm) | ម៉ោងចាប់ផ្តើម | ម៉ោងចប់ | លាងទឹកថ្លាឬទេ ? (បាទចាស/ទេ) | ធុំក្លិនមកពីដៃមួល នៅពេលបានបើកឬទេ ? (បាទចាស/ទេ) |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |